**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៥ សរណន

# សារាចរណែនាំ
## ស្តីពី
## ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩

### I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩

***ក- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច***

១- ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ នេះ ស្ថិតក្នុងបរិការណ៍ដ៏សំខាន់ពីរគឺ ការបោះឆ្នោតសកលជ្រើសរើសតំណាងរាស្រ្តអាណត្តិទី ៤ នៃរដ្ឋសភា និង ស្ថានភាពសេដ្ឋកិច្ចដែលបាន និង កំពុងរងនូវឥទ្ធិពលអតិផរណាដែលបណ្តាលមកពីការបន្តឡើងថ្លៃនៃប្រេងឥន្ធនៈ និង ម្ហូបអាហារលើទីផ្សារពិភពលោក និង រងនូវឥទ្ធិពលនៃការធ្លាក់ចុះនៃតំលៃរូបិយប័ណ្ណដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណនៃបណ្តាប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា ។ ទោះជាយ៉ាងណា សមិទ្ធផល និង បទពិសោធន៍ដែលរាជរដ្ឋាភិបាលបានកសាងក្នុងរយៈកាល ៣ អាណត្តិកន្លងទៅនេះ ជាពិសេស តាមរយៈការអនុវត្តយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលពី **យុទ្ធសាស្រ្តត្រីកោណ** មក **យុទ្ធសាស្រ្តចតុកោណ** និង ការអនុវត្តផែនការយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលពី **ផែនការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមលើកទី ១** និង **លើកទី ២** រហូតមកដល់ **ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** ពិតជាបានបង្កើតនូវមូលដ្ឋានដ៏រឹងមាំ សំរាប់ការបន្តពង្រឹង និង ជំរុញការអភិវឌ្ឍ ***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** ដែលជាកត្តាគន្លឹះដ៏សំខាន់បំផុតសំរាប់សំរេចអោយបានជោគជ័យនូវយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ សមិទ្ធផលទាំងនេះពិតជាឆ្លុះបញ្ចាំងអោយឃើញថា រាជរដ្ឋាភិបាលពិតជាមានគោលនយោបាយដ៏ត្រឹមត្រូវ មានការដឹកនាំដ៏ឈ្លាសវៃ និង មោះមុត និង មានប្រព័ន្ធត្រួតពិនិត្យលទ្ធផលប្រកបដោយប្រសិទ្ធភាព ។

២- តាមការគណនាចុងក្រោយរបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចគិតតាមថ្លៃថេរសំរាប់ឆ្នាំ ២០០៧ សំរេចបាន ១០,២% ធៀបនឹងការព្យាករណ៍ប្រមាណ ៧% នៅដើមឆ្នាំ គឺស្មើនឹង ៣៥ ០៣៩ ពាន់លានរៀល ។ កំណើននេះ បានមកដោយសារវិស័យកសិកម្មបានកើនប្រមាណ ៥% ដែលក្នុងនោះ ដំណាំស្រូវបានកើនប្រមាណ ៧,៥% វិស័យឧស្សាហកម្មបានកើនប្រមាណ ៨,៤% ដែលក្នុងនោះ ផលិតកម្មវាយនភ័ណ្ឌបានកើនប្រមាណ ១០% និង ផលិតកម្មសំណង់បានកើនប្រមាណៈ ៦,៧% និង វិស័យសេវាកម្មបានកើន

ប្រមាណ ១០,១% ដែលក្នុងនោះ សកម្មភាពទេសចរណ៍បានកើនប្រមាណ ១០% ។ ដូច្នេះ ក្នុងឆ្នាំ ២០០៧ កន្លងទៅនេះ រាជរដ្ឋាភិបាលរក្សាបាននូវការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ និង រូបិយវត្ថុ មួយដ៏ល្អ ដែលធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក៏តែអតិផរណាមធ្យមប្រចាំឆ្នាំត្រឹមប្រមាណ ៦,៥% និង អត្រាប្តូរប្រាក់មានស្ថិរភាពល្អក្នុងរង្វង់ប្រមាណ ៤ ០៦៨ រៀល ក្នុង ១ ដុល្លារអាមេរិក ទោះជាត្រូវរងឥទ្ធិពល នៃការឡើងថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិក៏ដោយ ។

៣- ក្នុងឆ្នាំ ២០០៨ នេះ តាមការព្យាករណ៍ចុងក្រោយ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានប្រមាណ ៧% ដូចការព្យាករណ៍ដើមឆ្នាំ ទាបជាងការអនុវត្តបានក្នុងឆ្នាំ ២០០៧ (១០,២%) ។ នេះជាសេណារីយោប្រកបដោយ ភាពប្រុងប្រយ័ត្នខ្ពស់ ក្រោយពីសង្កេតឃើញថា សេដ្ឋកិច្ចកម្ពុជាបាន និង កំពុងរងនូវឥទ្ធិពលប្រកួតប្រជែង ពីប្រទេស វៀតណាម និង ចិន រងនូវឥទ្ធិពលអតិផរណា ដែលកើតឡើងដោយសារការបន្តកើនឡើងនៃថ្លៃប្រេង ឥន្ធនៈ និង ថ្លៃម្ហូបអាហារនៅលើទីផ្សារអន្តរជាតិ ព្រមទាំងការធ្លាក់ចុះនៃតំលៃដុល្លារអាមេរិក ធៀបទៅនឹង រូបិយប័ណ្ណបរទេសមួយចំនួនដែលជាដៃគូពាណិជ្ជកម្មរបស់យើង ។ ទោះជាយ៉ាងណាក៏ដោយ វិស័យសំខាន់ៗ នៃសេដ្ឋកិច្ចកម្ពុជានឹងនៅតែបន្តកើនឡើង ទោះជាល្បឿននៃកំនើនលើវិស័យខ្លះអាចនឹងថយចុះបន្តិចក៏ដោយ ។ តាមសេណារីយោនេះ វិស័យកសិកម្មនឹងមានកំណើនប្រមាណ ៤,៥% ធៀបនឹង ៥% នៅក្នុងឆ្នាំ ២០០៧ (ក្នុងនោះ ដំណាំស្រូវនឹងកើនប្រមាណ ៧% ធៀបនឹង ៧,៥% នៅក្នុងឆ្នាំ ២០០៧) វិស័យឧស្សាហកម្មនឹង មានកំណើនត្រឹមប្រមាណ ៨% ធៀបនឹង ៨,៤% នៅក្នុងឆ្នាំ ២០០៧ (ក្នុងនោះ ផលិតផលវាយនភ័ណ្ឌ នឹងមានកំណើនត្រឹមប្រមាណ ៦% ធៀបនឹង ១០% នៅក្នុងឆ្នាំ ២០០៧ ហើយផលិតផលសំណង់នឹងមាន កំណើនត្រឹមប្រមាណ ៦% ធៀបនឹង ៦,៧% នៅក្នុងឆ្នាំ ២០០៧) វិស័យសេវាកម្មនឹងបន្តមានកំណើនប្រមាណ ១០% ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧ (ក្នុងនោះ អាជីវកម្មទេសចរណ៍ក៏នឹងនៅមានកំណើនប្រមាណ ១០% ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧) ។ អត្រាអតិផរណា អាចនឹងឡើងដល់ប្រមាណជាមធ្យម ២០% នៅក្នុងឆ្នាំ ២០០៨ នេះប្រសិនបើថ្លៃប្រេងឥន្ធនៈ និង ថ្លៃម្ហូបអាហារ នៅលើទីផ្សារអន្តរជាតិនៅតែបន្តកើនឡើង ហើយអត្រា ប្តូរប្រាក់នឹងអាចឡើងដល់ប្រមាណជាមធ្យម ៤ ១០០ រៀល ក្នុង ១ ដុល្លារអាមេរិក ។

៤- ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេលមធ្យម (២០០៩-២០១១) សេដ្ឋកិច្ចនឹងនៅតែអាច រក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% ស្របតាមគោលដៅ **យុទ្ធសាស្ត្រចតុកោណ** និង **ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។ តាមការព្យាករណ៍ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចជាមធ្យម សំរាប់រយៈពេលមធ្យមពីឆ្នាំ ២០០៩ ដល់ ២០១១ ខាងមុខ គឺអាចនឹងសំរេចបានប្រមាណ ៧% ដោយសារ វិស័យកសិកម្មនឹងនៅតែបន្តកើនឡើងជាមធ្យមប្រមាណ ៤% ដែលក្នុងនោះ ផលិតផលស្រូវនឹងនៅបន្តកើន ជាមធ្យមប្រមាណ ៤,៥% វិស័យឧស្សាហកម្មនឹងកើនជាមធ្យម ៧,៥% ដែលក្នុងនោះ ផលិតកម្មវាយនភ័ណ្ឌ នឹងនៅបន្តកើនជាមធ្យមប្រមាណ ៨% និង ផលិតកម្មសំណង់នឹងនៅបន្តកើនជាមធ្យមប្រមាណ ៦% និង វិស័យសេវាកម្មនឹងនៅបន្តកើនជាមធ្យមប្រមាណ ៨,៥% ដែលក្នុងនោះ សកម្មភាពទេសចរណ៍នឹងនៅបន្ត កើនជាមធ្យមប្រមាណ ៩% ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានត្រៀមនឹងប្រើវិធានការគោលនយោបាយ រូបិយវត្ថុ គោលនយោបាយថវិកា ដើម្បីបញ្ចុះ និង គ្រប់គ្រងអត្រាអតិផរណាក្នុងកំរិតមួយសមស្រប និង ដោយ ប្រុងប្រយ័ត្នបំផុត ដោយធានាកាត់បន្ថយក្នុងកំរិតអតិបរមានូវផលប៉ះពាល់អាក្រក់លើសេដ្ឋកិច្ចជាតិ និង

លើជីវភាពរបស់ប្រជាជន ។ រីឯអត្រាប្តូរប្រាក់ក៏ដូច្នេះដែរ រាជរដ្ឋាភិបាលក៏ត្រៀមនឹងប្រើវិធានការគោលនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាព និង កំរិតមួយសមស្រប គឺក្នុងរង្វង់ ៤០៥០ រៀល ក្នុង ១ ដុល្លារអាមេរិក ក្នុងទិសដៅធានាសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និង ធានារក្សាតុល្យភាពរវាងផលប្រយោជន៍អ្នកមានចំណូលជារៀល និង អ្នកមានចំណូលជាដុល្លារអាមេរិក ។

## ខ- *ស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ថវិកា*

៥- ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រុងប្រយ័ត្ន ត្រូវបានផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្រប និង ជាពិសេស ការបន្តអនុវត្តកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈយ៉ាងមោះមុត គ្រប់ជ្រុងជ្រោយ និង ជាជំហានៗ យ៉ាងច្បាស់លាស់ បានធ្វើអោយលទ្ធផលកំណើនសេដ្ឋកិច្ច លទ្ធផលវិស័យហិរញ្ញវត្ថុ និង ធនាគារ ព្រមទាំងលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ ២០០៧ សំរេចបានយ៉ាងល្អប្រសើរគួរជាទីមោទនៈ ។ ជាក់ស្តែង កំណើនសេដ្ឋកិច្ចឆ្នាំ ២០០៧ សំរេចបានរហូតដល់ ១០,២% ធៀបនឹងការព្យាករណ៍ដើមឆ្នាំ ៧% ។ វិស័យហិរញ្ញវត្ថុ និង ធនាគារបាន និង កំពុងមានការរីកចំរើនគួរអោយកត់សំគាល់ តាមរយៈការរីកដុះដាលនៃធនាគារពាណិជ្ជ ការកើនឡើងនៃប្រាក់បញ្ញើធនាគារ ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធ និង សេវាធនាគារ និង ការពង្រឹងការគ្រប់គ្រងធនាគារ ដែលជាមូលដ្ឋានដ៏សំខាន់សំរាប់ឈានទៅរកការរៀបចំមូលបត្ររដ្ឋ និង មូលបត្រឯកជន និង ការបង្កើតទីផ្សារភាគហ៊ុននៅកម្ពុជា ។

៦- នៅឆ្នាំ ២០០៧ កន្លងទៅនេះ ចំណូលក្នុងស្រុកសរុបសំរេចបាន ១២៤,៣% គឺមានកំនើន ២៤,៥% ធៀបនឹងឆ្នាំ ២០០៦ ហើយស្មើនឹង ១២% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធសំរេចបាន ១២៩,១% ស្មើនឹង ១០,២% នៃផសស មានកំណើន ៤០% ធៀបនឹងឆ្នាំ ២០០៦ និង ចំណូលមិនមែនសារពើពន្ធសំរេចបាន ១០៦,៦% ស្មើនឹង ១,៨% នៃផសស កើនឡើងប្រមាណ ៣០,៥% ធៀបនឹងឆ្នាំ ២០០៦ ។ រីឯការអនុវត្តចំណាយវិញក៏មានលក្ខណៈល្អប្រសើរផងដែរ ជាក់ស្តែង ចំណាយសរុបឆ្លងកាត់រតនាគារជាតិអនុវត្តបាន ៩៩,៣% មានកំនើន ២២,៣% ធៀបនឹងឆ្នាំ ២០០៦ ស្មើនឹង ១០,៣% នៃផសស ដែលក្នុងនោះ ចំណាយចរន្តអនុវត្តបាន ១០២,៨% មានកំណើន ២០% និង ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេសអនុវត្តបាន ៧៦,៧% មានកំណើន ១៥,៨% ធៀបនឹង ឆ្នាំ ២០០៦ រីឯចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តបាន ១១៧% ថយចុះប្រមាណ ២% ធៀបនឹង ឆ្នាំ ២០០៦ ។ ទន្ទឹមនឹងនេះ ចំណាយតាមវិស័យដែលអនុវត្តបានគឺ វិស័យរដ្ឋបាលទូទៅសំរេចបាន ១០៨,៤% កើនឡើង ២៧,៥% ធៀបនឹងឆ្នាំ ២០០៦ ស្មើនឹង ១,៦% នៃផសស វិស័យការពារជាតិ និង សន្តិសុខសំរេចបាន ១២១,៤% កើនឡើង ១៨,៤% ធៀបនឹងឆ្នាំ ២០០៦ ស្មើនឹង ១,៨% នៃផសស វិស័យសេដ្ឋកិច្ចសំរេចបាន ១០៥,៩% កើនឡើង ១១,២% ធៀបនឹងឆ្នាំ ២០០៦ ស្មើនឹង ០,៨% នៃផសស និង វិស័យសង្គមកិច្ចសំរេចបាន ៩៦,៣% កើនឡើង ១៨,៨% ធៀបនឹងឆ្នាំ ២០០៦ ស្មើនឹង ៣% នៃផសស ។ លទ្ធផលនៃការអនុវត្តចំណូល និង ចំណាយនេះ បានធ្វើអោយមានអតិរេកចរន្តស្មើនឹង ៣,៨៦% និង ឱនភាពថវិកាសរុបស្មើនឹង ១,៩៤% នៃផសស ។

៧- ទោះជាកំណើនសេដ្ឋកិច្ចឆ្នាំ ២០០៨ អាចនឹងសំរេចបានត្រឹមប្រមាណ ៧% ធៀបនឹងការអនុវត្តបានជាក់ស្តែងក្នុងឆ្នាំ ២០០៧ ដែលមានរហូតដល់ ១០,២% ក៏ដោយ តែបើធៀបនឹងការព្យាករណ៍ដើមឆ្នាំ និង ការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច គឺយើងនៅតែមានសុទិដ្ឋិនិយមលើកំណើន ហើយក៏ជាសេណារីយោប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ផងដែរ ដោយសារឥទ្ធិពលនៃការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌពីប្រទេសវៀតណាម និង ចិន ការឡើងថ្លៃនៃប្រេងឥន្ធនៈ និង ម្ហូបអាហារ និង ការធ្លាក់ចុះនៃដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណនៃបណ្តាប្រទេសដៃគូពាណិជ្ជកម្មកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ យើងសង្ឃឹមថានឹងមិនមានឥទ្ធិពលជាអវិជ្ជមានធ្ងន់ធ្ងរមកលើស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ពិសេស លើការអនុវត្តថវិកាឡើយ ព្រោះរាជរដ្ឋាភិបាលបានដាក់ វិធានការមួយចំនួនដើម្បីរក្សាគំរិតចំណូល និង ចំណាយទៅតាមច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ និង បានត្រៀមជាស្រេចនូវវិធានការសំរាប់បង្កើនចំណូល ឬ/និង កាត់បន្ថយចំណាយក្នុងករណីចាំបាច់ ។ ចំណូលក្នុងស្រុកសរុបអាចនឹងសំរេចបាន ១២% នៃផសស គឺប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧ ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសំរេចបាន ១០% នៃផសស និង ចំណូលមិនមែនសារពើពន្ធនឹងសំរេចបាន ១,៧% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧ និង ចំណូលមូលធននឹងសំរេចបានប្រមាណ ៣,៧% នៃផសស ថយចុះប្រមាណ ០,៥% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ។ ចំណាយសរុបអាចនឹងសំរេចបាន ១៤,៤% នៃផសស កើនប្រមាណ ០,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ដែលក្នុងនោះ ចំណាយចរន្តនឹងសំរេចបាន ៩% នៃផសស កើនឡើង ០,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៧ និង ចំណាយមូលធនអាចនឹងសំរេចបាន ៥,៤% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧ ។ ការអនុវត្តចំណូល និង ចំណាយនេះ អាចនឹងធ្វើអោយមានអតិរេកចរន្តប្រមាណ ២,៨% នៃផសស និង ឱនភាពថវិកាសរុបប្រមាណ ២,៤% នៃផសស ។

៨- ការបន្តពង្រឹង និង បង្កើនសមត្ថភាព និង ប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល និង ចំណាយក្នុងក្របខ័ណ្ឌ **កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ការអនុវត្តចំណូល និង ចំណាយឆ្នាំ ២០០៨ សង្ឃឹមថានឹងទទួលបានលទ្ធផលកាន់តែល្អប្រសើរជាងឆ្នាំ ២០០៧ មួយកំរិតបន្ថែមទៀត ។ ជាក់ស្តែងលទ្ធផលនៃការប្រមូលចំណូលត្រីមាសទី ១ បានបង្ហាញអោយឃើញថា ចំណូលក្នុងស្រុកសរុបសំរេចបាន ៣០% នៃផែនការឆ្នាំ ដែលក្នុងនោះចំណូលគយ និង រដ្ឋាករសំរេចបាន ២៩,៣% ពន្ធដារសំរេចបាន ២៩,៨% និង ចំណូលមិនមែនសារពើពន្ធសំរេចបាន ៣៦,៤% ។ រីឯចំណាយ សរុបឆ្លងកាត់រតនាគារជាតិ ត្រីមាសទី ១ សំរេចបាន ១៤,៩% ធៀបនឹងត្រីមាសទី ១ ឆ្នាំ ២០០៧ ដែលអនុវត្តបានតែប្រមាណ ១២,៨% ប៉ុណ្ណោះ ហើយចំណាយនៅក្នុងត្រីមាសទី ២ ប្រាកដជាខ្ពស់ជាងត្រីមាសទី ១ ដែលជារបត់ចំណាយប្រចាំឆ្នាំ ។

## II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៩

### ក. *ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៩- ទោះជាឆ្នាំ ២០០៩ គឺជាឆ្នាំទី ១ របស់រាជរដ្ឋាភិបាលអាណត្តិទី ៤ ក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែយល់ឃើញថា ការបន្តរក្សាអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ពី ៦ ទៅ ៧ ភាគរយ ប្រកបដោយចីរភាព និង ការបន្តរក្សាអោយបាននូវស្ថិរភាពនយោបាយ និង ម៉ាក្រូសេដ្ឋកិច្ច នៅតែជាមូលដ្ឋានគន្លឹះ

និង ចាំបាច់បំផុត ក្នុងការឈានទៅសំរេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ការកាត់បន្ថយភាពក្រីក្រ ភាពសុខដុមរមនា និង សុភមង្គលរបស់ប្រជាជន*** ។ ដើម្បីសំរេចបានតាមគោលដៅខាងលើ រាជរដ្ឋាភិបាលនឹងត្រូវបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០** ដែលផ្អែកលើ **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ។ រាជរដ្ឋាភិបាលនឹងត្រូវបន្តជំរុញការអភិវឌ្ឍតាមវិស័យ ដូចជា ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចដែលត្រូវផ្តោតលើកសិកម្ម កសិឧស្សាហកម្ម និង ការអភិវឌ្ឍ ជនបទ ការអភិវឌ្ឍវិស័យសង្គមកិច្ចដែលត្រូវផ្តោតលើការអប់រំ សុខាភិបាល និង ការកសាងធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលត្រូវផ្តោតលើផ្លូវ ថ្នល់ ស្ពាន និង ប្រព័ន្ធធារាសាស្ត្រ និង ការអភិវឌ្ឍវិស័យឯកជន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងត្រូវបន្តជំរុញការអនុវត្តបណ្តាកម្មវិធីកែទំរង់លើគ្រប់វិស័យ អោយបានកាន់តែស៊ីជំរៅ ដូចជា ការកែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីសំរេចបាននូវការគ្រប់គ្រងប្រកប ដោយអភិបាលកិច្ចល្អ និង ការផ្តល់សេវាសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់ ។

១០- ឆ្នាំ ២០០៩ គឺជាឆ្នាំដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែបន្តវិវត្តផ្លាស់ប្តូររចនាសម្ព័ន្ធ ដើម្បីឈានទៅរកដំណាក់កាលនៃការអភិវឌ្ឍមួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការរីកធំធាត់ជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និង សេវាកម្ម នៅក្នុងរចនាសម្ព័ន្ធផលិតផលក្នុងស្រុកសរុប ។ ប្រការនេះ ទាមទារអោយមានការបន្តពង្រីកមូលដ្ឋាននៃកំណើន តាមរយៈការលើកស្ទួយវិស័យកសិកម្ម និង ការពង្រឹងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ដើម្បីបង្កើនតំលៃបន្ថែមលើផលិតកម្ម និង ស្រូបយកពលកម្មដែលត្រូវបន្តផ្ទេរជាបន្តបន្ទាប់ពីវិស័យកសិកម្ម ។ ធ្វើយ៉ាងនេះ ទើបអាចធានាការបន្តរក្សាបាននូវចីរភាព និង សមធម៌នៃកំណើនសេដ្ឋកិច្ចបាន ។ ដូច្នេះ នៅក្នុងរយៈពេលមធ្យម (២០០៩-២០១១) កំណើនសេដ្ឋកិច្ចកម្ពុជានឹងបន្តកើនឡើង ក៏ប៉ុន្តែនឹងកើនក្នុងល្បឿនមួយយឺតជាងមុន ហើយល្បឿននេះអាស្រ័យដោយល្បឿននៃការបង្កើនផលិតភាពកសិកម្ម និង ការពង្រីក និង ពង្រឹងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ។ ទោះជាយ៉ាងណាក៏ដោយ មូលដ្ឋានសេដ្ឋកិច្ចនឹងនៅតែអាចរក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% នៅក្នុងរយៈពេលមធ្យមនេះ ។ តាមការព្យាករណ៍ ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៩ ខាងមុខនេះ អាចនឹងសំរេចបានត្រឹមប្រមាណ ៦,៥% ដោយសារវិស័យកសិកម្មនឹងកើនឡើង ៤,៥% ដែលក្នុងនោះ ផលិតផលស្រូវនឹងកើនឡើងប្រហាណ ៤,៩% វិស័យឧស្សាហកម្មនឹងកើនឡើង ៨% ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងកើនឡើងប្រមាណ ៨,៥% និង ផលិតផលសំណង់នឹងកើនឡើង ៦,៥% និង វិស័យសេវាកម្មនឹងកើនឡើង ៨,៥% ដែលក្នុងនោះ ទេសចរណ៍នឹងកើនឡើងប្រមាណ ៩% ។

***ខ- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា***

១១- ដោយផ្អែកលើមូលដ្ឋាននៃ **យុទ្ធសាស្ត្រចតុកោណ** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ថវិកាឆ្នាំ ២០០៩ មានគោលដៅសំខាន់ៗ ដូចតទៅ ÷

• ធានាអោយបាននូវការអនុវត្តទិសដៅគោលនយោបាយ និង កម្មវិធីយុទ្ធសាស្ត្រជាអាទិភាពតាមវិស័យ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស គោលនយោបាយ កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

• ធានាការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការអភិវឌ្ឍវិស័យអាទិភាព ដូចជា វិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការអភិវឌ្ឍវិស័យឯកជន ដើម្បីជំរុញកំណើន និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

• ធានាបំរើអោយការបន្តសកម្មភាពកែទំរង់ស៊ីជំរៅរបស់រាជរដ្ឋាភិបាល លើគ្រប់ផ្នែក ដូចជា កំណែទំរង់រដ្ឋបាលសាធារណៈ កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទំរង់ច្បាប់ និង ប្រព័ន្ធតុលាការ កំណែទំរង់វិស័យកងទ័ព និង ការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និង បង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

• ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ (២០០៩-២០១១)

• ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់គុណភាពសេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ សុខាភិបាល និង ការកសាងធនធានមនុស្ស ។

• ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំរើអោយវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍជនបទ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

១២- ដើម្បីសំរេចបានតាមគោលដៅនៃទិសដៅគោលនយោបាយខាងលើ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តបណ្តាគោលនយោបាយ និង កម្មវិធីកែទំរង់សំខាន់ៗ ដូចខាងក្រោម៖

*ក.* បន្តអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈដ៏ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសំរេចអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចីរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាសមស្រប ។ ជាពិសេស រាជរដ្ឋាភិបាលបានត្រៀមជាស្រេចនូវវិធានការគោលនយោបាយរូបិយវត្ថុមួយចំនួន សំរាប់ទប់ទល់នឹងអតិផរណា ក្នុងករណីចាំបាច់ តែនឹងមិនអោយប៉ះពាល់ធ្ងន់ធ្ងរដល់អត្រាកំណើនដែរ ។

*ខ.* បន្តជំរុញការអភិវឌ្ឍតាមវិស័យ ពិសេស វិស័យសេដ្ឋកិច្ច សង្គមកិច្ច ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការអភិវឌ្ឍវិស័យឯកជន ។ ត្រូវផ្តោតលើការលើកស្ទួយវិស័យកសិកម្ម កសិឧស្សាហកម្ម និង ជួយគាំទ្រដល់សហគ្រាសធុនតូច និង មធ្យម ។ បន្តយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំ សុខាភិបាល និង ការកសាងធនធានមនុស្ស ។ បន្តជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសប្រព័ន្ធស្រោចស្រព ។ បង្កបរិយាកាស និង ផ្តល់ការលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជន ។

*គ.* បន្តអនុវត្តនូវកំណែទម្រង់ការគ្រប់គ្រងដីធ្លី ដើម្បីជួយគាំទ្រដល់វិស័យកសិកម្មអោយសមស្រប តាមច្បាប់ភូមិបាល ដើម្បីឱ្យវិស័យនេះក្លាយទៅជាមូលដ្ឋានរឹងមាំនៃកំណើនសេដ្ឋកិច្ច និង បំរើគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ។

*ឃ.* បន្តអនុវត្តកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការបន្តពង្រឹងភាពជឿទុកចិត្តលើថវិកា នៃជំហានទី ១ តាមរយៈការបន្តជំរុញការកែលំអនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រង

សាច់ប្រាក់ ដើម្បីធានាអោយការបើកផ្តល់ថវិកាបានទាន់ពេលវេលា និង ការបន្តកសាងក្របខ័ណ្ឌគោលនយោបាយចំណូលរយៈពេលមធ្យមដើម្បីរក្សាស្ថិរភាព និង និរន្តរភាពចំណូល ។ ទន្ទឹមនឹងនេះ ត្រូវបន្តជំរុញការរៀបចំបញ្ចប់នូវផែនការសកម្មភាព ជាពិសេស ផែនការសកម្មភាពរបស់គ្រប់ក្រសួង-ស្ថាប័ន ដែលត្រូវចូលរួមធ្វើជាម្ចាស់ និង ការទទួលខុសត្រូវក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួន នៅក្នុងជំហានទី ២ ខាងមុខនេះ គឺការបង្កើតគណនេយ្យភាពហិរញ្ញវត្ថុ ។ លើសពីនេះទៅទៀត ត្រូវបន្តជំរុញការពង្រឹង និង បង្កើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និង ថវិកាតាមកម្មវិធី ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងជាគោលដៅនៃជំហានទី ៣ និង ទី ៤ ។

៥. បន្តពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីកៀងគរធនធានហិរញ្ញវត្ថុសម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន ។

៦. កសាង និង ពង្រឹងការអនុវត្តច្បាប់ និង លិខិតបទដ្ឋាននានា ជាពិសេសពង្រឹងរចនាសម្ព័ន្ធស្ថាប័ន និង បំពេញកាតព្វកិច្ចកម្ពុជា ក្នុងឋានៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីទាញប្រយោជន៍ពីសមាជិកភាពនេះអោយបានជាអតិបរមា ។

៧. បន្តជម្រុញអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ពិសេស ការរៀបចំច្បាប់ និង លិខិតបទដ្ឋានផ្សេងៗ ដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងន័យនេះ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ និង ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសហការរៀបចំកម្មវិធីសកម្មភាពអោយបានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ជាជំហានៗ ប្រកបដោយភាពហ្មត់ចត់ និងប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាការអនុវត្តប្រកបដោយភាពរលូន និងប្រសិទ្ធភាព ។ ពិសេស ការពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុរបស់គ្រប់ស្ថាប័ន និង អង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការផ្ទេរអំណាច និង ការទទួលខុសត្រូវពីថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព ។

៨. បន្តជម្រុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ រួមមានការពង្រឹង និង ពង្រីកការអនុវត្តកន្សោមអាទិភាព និង ការផ្តល់លាភការតាមសមិទ្ធកម្ម ដើម្បីបង្កើនផលិតភាព និង ប្រសិទ្ធភាពការងារ ។

## III. ការគណនា និង ទិសដៅថវិកាឆ្នាំ ២០០៩

### ក- គំរោងចំណាយថវិកា

១៣- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅទាំងអស់ខាងលើ និង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០០៩ ត្រូវគ្រោងបើមូលដ្ឋានយុទ្ធសាស្ត្រ និង វិធានការដូចខាងក្រោម៖

• បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ និង ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបអោយស្ថិតនៅក្នុងកំរិត ១៥% នៃផសស គឺកើនឡើងប្រមាណ ០,៦% នៃផសស ដែលក្នុងនោះ ចំណាយចរន្តសរុបនឹងត្រូវបានរក្សាអោយនៅត្រឹមប្រមាណ ៩,៦% នៃផសស និង ចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៥,៥% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,៨% នៃផសស និង ឱនភាពថវិកាសរុបក្នុងរង្វង់ ៣% នៃផសស ។ ដោយឡែក ចំណាយ

មូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ១,៦% នៃផសស ហើយចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវកំណត់ក្នុងចំនួន ៣,៦% នៃផសស ។ ទន្ទឹមនឹងនេះ ចំណាយសំរាប់រំលស់បំណុលត្រូវកំណត់ត្រឹម ០,៣% នៃផសស ។

- ត្រូវវិភាជន៍ចំណាយចរន្តទៅតាមវិស័យនីមួយៗ ដូចតទៅៈ វិស័យសង្គមកិច្ចស្មើនឹង ៣,៧% នៃផសស មានកំណើនប្រមាណ ០,៤% នៃផសស ធៀបនឹងការព្យាករណ៍អនុវត្តឆ្នាំ ២០០៨ វិស័យសេដ្ឋកិច្ច ១% នៃផសស មានកំណើនប្រមាណ ០,៣% នៃផសស ធៀបនឹងការព្យាករណ៍អនុវត្តឆ្នាំ ២០០៨ វិស័យរដ្ឋបាលទូទៅ ១,៦% នៃផសស ប្រហាក់ប្រហែលនឹងការព្យាករណ៍អនុវត្តឆ្នាំ ២០០៨ វិស័យការពារជាតិ និង សន្តិសុខ ១,៦% នៃផសស ប្រហាក់ប្រហែលនឹងការព្យាករណ៍អនុវត្តឆ្នាំ ២០០៨ ។ ថវិកាផ្ទាល់របស់ខេត្ត-ក្រុងសរុបមានប្រមាណ ០,៦% នៃផសស ប្រហាក់ប្រហែលនឹងការព្យាករណ៍អនុវត្តឆ្នាំ ២០០៨ ។

១៤- ថវិកាឆ្នាំ ២០០៩ ខាងមុខនេះ ត្រូវបំរើគោលនយោបាយរាជរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច និង ការលើកស្ទួយជីវភាពនៅទីជនបទ សំដៅសំរេចនូវការអភិវឌ្ឍប្រកបដោយចីរភាព និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០០៩ ត្រូវផ្តល់ការវិភាជជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗដូចខាងក្រោមៈ

- បន្តបង្កើនថវិកាសំរាប់វិស័យអប់រំ និង សុខាភិបាលអោយស្របទៅតាមគោលដៅនៃកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យអប់រំ និង សុខាភិបាលឆ្នាំ ២០០៩-២០១១ ។
- បន្តបង្កើនថវិកាសម្រាប់ការអភិវឌ្ឍប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍកសិកម្ម និង ការអភិវឌ្ឍជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យសេដ្ឋកិច្ចដើម្បីកំណើន សមធម៌ និង ការកាត់បន្ថយភាពក្រីក្រ ។
- បង្កើនមូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ ២០០៩ ដល់ ២,៧៥% នៃចំណូលចរន្តថវិការដ្ឋឆ្នាំ ២០០៨ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ស្របតាមអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំសង្កាត់ ។
- បន្តផ្តល់អាទិភាពនៃការវិភាជថវិកាដល់ថវិកាតាមកម្មវិធី និង ផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានបញ្ជាក់ពីទិសដៅគោលនយោបាយ គោលបំណង កម្មវិធី និង/ឬ យុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និង សូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និង បង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ការបន្តពង្រឹង និង ការកែលំអការរៀបចំ និង ការអនុវត្តថវិកាតាមកម្មវិធី ។

**ខ- គំរោងចំណូលថវិកា**

១៥- ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃគំរោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយចំណូល និង ការអនុវត្តអោយបានសំរេចទៅតាមផែនការសកម្មភាព និង គោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសំរេចអោយបាននូវកំរិតចំណូលក្នុងស្រុកសរុបប្រមាណ ១២,០៤% នៃផសស គឺប្រហាក់ប្រហែលនឹងឆ្នាំ ២០០៨ ដែលក្នុងនោះ ចំណូលសារពើពន្ធ ត្រូវសំរេចអោយ

បាន ១០,២៨% នៃផសស គឺមានកំណើន ០,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៨ ចំណូលមិនមែនសារពើពន្ធត្រូវសំរេចអោយបាន ១,៦៦% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៨ និង ចំណូលមូលធនក្នុងស្រុកត្រូវសំរេចអោយបាន ០,១០% នៃផសស ។

១៦- ដើម្បីសំរេចបានតាមគោលដៅនៃការប្រមូលចំណូលសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តអនុវត្តសកម្មភាពការងារ និង បណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតទៅលើបណ្តាវិធានការសំខាន់ៗមួយចំនួនដូចខាងក្រោម ÷

**ទី១- ផ្នែកចំណូលពន្ធដារ:**

- បន្តពង្រឹង និង កែលំអរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និង ការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។
- បន្តពង្រឹងការអនុវត្តកម្មវិធីកែលំអរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងប្រតិបត្តិការរបស់នាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានពន្ធដារ ។
- បន្តបញ្ចប់ការកសាង និង ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។
- បន្តពង្រឹងការអនុវត្តអោយបានគ្រប់ជ្រុងជ្រោយ និង ឱ្យបានហ្មឹងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។
- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និង ពង្រឹងការអនុវត្តរបបពិតនៅតាមបណ្តា ខេត្ត- ក្រុង និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។
- បន្តបណ្តុះបណ្តាល និង បង្កើនសមត្ថភាពវិជ្ជាជីវៈ និង សីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម ។
- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និង ឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និង ឧស្ម័ន ។
- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។
- បន្តពង្រឹងអភិបាលកិច្ចរបស់នាយកដ្ឋានពន្ធដារ ។

**ទី២- ផ្នែកចំណូលពន្ធគយ:**

- បន្តជំរុញការរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់គយដែលទើបបានទទួលការអនុម័ត ។

- បន្តកែលំអនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុម-ហ៊ុននាំចេញ- ចូល និង ក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និង ភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ។

- បន្តរៀបចំកែលំអ និងដាក់អោយអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់ទីចាត់ការគយ និងរដ្ឋាករ ។

- អនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

*ក. បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ* ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និង អាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និង ប្រកបដោយប្រសិទ្ធភាពថែមទៀត ក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ ជាពិសេស លើវិធានការកែលំអផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេយិតភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារអេឡិចត្រូនិច និង ការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

*ខ. បន្តពង្រឹងការសហការជាមួយនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរព័ត៌មាន* រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង កាតព្វកិច្ចពន្ធដារ ។

*គ. បន្តរិះរក និង ដាក់អោយអនុវត្តនូវវិធានការច្បាស់លាស់ និង ទន់ភ្លន់* លើមុខទំនិញមួយចំនួនដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងហ្មត់ចត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិ៍ៈ បន្តការបណ្តុះ-បណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តពង្រឹង និង ពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និង យន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលំអប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្ម ជូនដល់អតិថិជន ។

- បន្តពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និង ការប្រមូលចំណូល ។

- បន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលគយ និង រដ្ឋាករ ។

**ទី៣- ផ្នែកចំណូលមិនមែនសារពើពន្ធ:**

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេស បទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

- បន្តស្រាវជ្រាវ និង កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និង បណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូល ពីប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរណ៍ស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រសហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការប្រមូលចំណូល។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតំរូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

១៧- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ជាមួយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៨ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៨ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីអោយបាននៅក្នុងសប្តាហ៍ទី១ នៃ ខែតុលា ឆ្នាំ ២០០៨ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច ហើយផ្ញើជូនរដ្ឋសភាអោយបានក្នុងសប្តាហ៍ទី១ នៃ ខែវិច្ឆិកា ឆ្នាំ ២០០៨ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ ពិភាក្សា និង អនុម័តសេចក្តីព្រាងច្បាប់នេះអោយបានមុនថ្ងៃ ២៥ ខែធ្នូ ២០០៨ ។

## គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩

១៨- ការអនុវត្តកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើអោយប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ នូវការគ្រប់គ្រងចំណូល និង ចំណាយ ជាពិសេស រាជរដ្ឋាភិបាល បានដោះស្រាយបំណុលចាស់ទាំងស្រុង និង បានបញ្ឈប់ប្រពៃណីខ្វះសាច់ប្រាក់ទូទាត់ចំណាយផងដែរ ។ ទោះជាយ៉ាងនេះក៏ដោយ យើងនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តជំរុញ ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូល ដើម្បីបំពេញតម្រូវការចំណាយ ដែលចេះតែកើនឡើងជាលំដាប់ រួមមានដូចជា៖

*ទី១-* ការបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា អោយបានសមស្រប ដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ហើយពង្រឹងការរៀបចំថវិកាអោយបានគ្រប់ជ្រុងជ្រោយ និង សុក្រឹត ដើម្បីកាត់បន្ថយជាអតិបរមានូវចំណាយមិនបានគ្រោងទុក និង

សំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និង ចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយភាពជឿទុកចិត្តបាន គណនេយ្យភាព និង ប្រសិទ្ធភាព ។

*ទី២* ការបន្តជំរុញការរៀបចំកម្មវិធីចំណូល- ចំណាយអោយបានសុក្រឹត និង ការអនុវត្តអោយបានហ្មឹងម៉ាត់ ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ធានាបង្កើនភាពជឿទុកចិត្តបាន និង គណនេយ្យភាពលើការអនុវត្តថវិកា ។ លើសពីនេះ ការបង្កើនការគោរពយ៉ាងហ្មឹងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស វិន័យថវិកាទាំង ១០ ។

*ទី៣* បន្តពង្រឹងការគ្រប់គ្រងបំណុល ជាពិសេស ការកសាងទិន្នន័យ និង ការរៀបចំកម្មវិធីសងបំណុលអោយបានច្បាស់លាស់ និង ដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំថវិកា និង ការបន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវការខ្ចីតែឥណទានដែលបំរើអោយគោលនយោបាយអាទិភាព ។

*ទី៤* បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ជាពិសេស ចំពោះគោលនយោបាយអាទិភាព ដូចជា អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត មាន ផ្លូវថ្នល់ ស្ពាន និង ប្រព័ន្ធស្រោចស្រព ដែលជាគោលបំណងនៃគោលនយោបាយ និង ជាទិសដៅយុទ្ធសាស្រ្តអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

*ទី៥* ការប្រឈមនឹងស្ថានភាពសេដ្ឋកិច្ចពិភពលោក ដែលជះឥទ្ធិពលមកលើការអនុវត្តថវិកាជាពិសេស បញ្ហាអតិផរណាដោយសារការឡើងថ្លៃនៃប្រេងឥន្ធនៈ និង ម្ហូបអាហារលើទីផ្សារពិភពលោក និង ការធ្លាក់ចុះនៃតំលៃរូបិយប័ណ្ណអាមេរិក ធៀបនឹងរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មកម្ពុជា ។

## III- នីតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០០៩

### ក- ការគ្រោងចំណូលថវិកាឆ្នាំ ២០០៩

១៩- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង បណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ចនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និង ពិចារណាទៅលើអត្រា និង មូលដ្ឋានប្រមូលពន្ធ
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និង កែលំអរដ្ឋបាល និង គោលនយោបាយពន្ធដារ គយ និង រដ្ឋាករ ការធ្វើចារណកម្មសារពើពន្ធ និង ការប្រមូលបំណុលពន្ធដែលត្រូវទារ ។

• ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលចុន ដូចជា កិច្ចសន្យាជួលសេវាកម្ម ការពង្រឹង និង កែលំអការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

## ខ- ការគ្រោងចំណាយថវិកាឆ្នាំ ២០០៩

២០- ការរៀបចំគំរោងឥណទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីគណនាតំរូវការថវិកាដោយលំអិតទៅតាម ជំពូក គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដោយផ្អែកលើតំរូវការជាក់ស្តែង និង ដោយផ្ទាល់ សំរាប់បំរើអោយការអនុវត្តកម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ រីឯការគណនាឥណទានចំណាយ ត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតំលៃសំភារៈនៃការផ្គត់ផ្គង់ និង ត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬ សេចក្តីណែនាំ ដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សាសំរាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសំរាប់ការគ្រប់គ្រងកន្លងមក ។ ជាពិសេស តំរូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និង មានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាម ជំពូក គណនី និង អនុគណនីនីមួយៗ ។

## គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០៩

២១- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកា ដោយកំណត់គោលការណ៍ចំណាយទៅតាមប្រភេទ និង ជំពូក ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា សំរាប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ធ្វើជាមូលដ្ឋានក្នុងការរៀបចំគំរោងចំណាយលំអិតទៅតាម គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ដើម្បីបំរើអោយតំរូវការជាក់ស្តែងក្នុងការអនុវត្តកម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃឆមាសទី ១ ឆ្នាំ ២០០៩ នេះ នឹងមិនមានការអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ នៅតាមខេត្ត-ក្រុងទេ ។

២២- ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និង បណ្តាវិធានការដូចខាងក្រោម៖

ក- ចំណាយបន្ទុកបុគ្គលិក ត្រូវគ្រោងដោយបង្កើន ២០% លើបៀវត្សមូលដ្ឋាន ទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និង តាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៨ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់

រាជរដ្ឋាភិបាល និង តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មិនត្រូវគិតអតិថរណានៅក្នុងចំណាយបៀវត្សនេះទេ ។ ចំពោះ បុគ្គលិកអណ្តែត និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង - ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ជ្រើសរើស និង ប្រើប្រាស់ ។

ខ- ចំណាយដំណើរការលើការទិញ និង សេវា ត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និង សន្សំសំចៃបំផុត ជាពិសេស ចំពោះសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវ មិនត្រូវបង្កើនចំណាយលើសពីឆ្នាំកំពុងអនុវត្តទេ ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនអោយមានចំណាយលើសពីឥណទានថវិកាដែលបានគ្រោងសំរាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយខ្ចីទំនិញ ឬ សេវាមកប្រើប្រាស់នៅក្រៅបរិបថនៃថវិកាទេ ។ កន្លងមកចំណាយសំរាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវមានលក្ខណៈខ្វះខាត ។ ចំណាយសំរាប់មុខសញ្ញាទាំងនេះចេះតែកើនឡើង ហើយការទូទាត់មិនបានទាន់ពេលវេលាដែលនាំអោយមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយអគ្គិសនី ទូរស័ព្ទ និង ទឹក ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និង ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក អោយបានត្រឹមត្រូវ ម៉ត់ចត់ និង ប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្លំចរន្តអគ្គិសនី ទូរស័ព្ទ និង ទឹក ប្រើប្រាស់ផ្ទាល់ខ្លួនខុសមុខសញ្ញារបស់ក្រសួង ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និង ចំពោះមុខរដ្ឋសភា ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនទូរស័ព្ទ ត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និង ចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសំរាប់អគ្គិសនី ទូរស័ព្ទ និង ទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុនធ្វើជាពិតាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះអោយចុះមកនៅក្នុងកំរិតមួយសមស្រប តាមការចាំបាច់ពិតប្រាកដរបស់ក្រសួងស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក្កយបត្រប្រចាំខែនីមួយៗ អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់វិក្កយបត្រ និង រៀបចំទូទាត់អោយបានទៀងទាត់ និង ទាន់ពេលវេលារៀងរាល់ខែ ។ ហាមដាច់ខាតមិនអោយមានការពន្យារការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការួមទេ ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និង គ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ហើយដាក់ឱ្យគ្រប់ក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាលអនុវត្តឱ្យបានខ្ជាប់ខ្ជួន និង ហ្មឹងម៉ាត់បំផុត ។

**គ-** ចំពោះចំណាយសំរាប់ជំពូក គណនី និង អនុគណនីផ្សេងៗទៀត ត្រូវគ្រោងទៅតាមតំរូវការ ចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តថវិកា ក្នុងករណី តំរូវអោយមានកំណើន ដោយមានការវិភាគ និង ពន្យល់ច្បាស់លាស់ ក៏កំណើននោះមិនត្រូវអោយលើសពី ៥% នៃគញ្ចប់ថវិកាដែលបានអនុម័តឆ្នាំ ២០០៨ ដែរ ។ ចំពោះក្រសួងដែលត្រូវបន្ត ឬ ចាប់ផ្តើមអនុវត្ត សាកល្បងថវិកាតាមកម្មវិធី ត្រូវញែកគំរោងចំណាយជាពីរផ្នែកសំរាប់ថវិកាកម្មវិធី និង ថវិកាមិនមែនកម្មវិធី ទៅតាមគ្រប់ ជំពូក គណនី និង អនុគណនីនីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំង នេះមកការពារគំរោងថវិកាតាមកម្មវិធីដោយឡែក ។

**ឃ-** ឯកសារផែនការយុទ្ធសាស្រ្តថវិកា គំរោងចំណូល និង គំរោងចំណាយថវិកា ដែលក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាមូលដ្ឋានសំរាប់ការពិភាក្សា នៅក្នុងកិច្ចប្រជុំការពារថវិកា ដើម្បីការពារគញ្ចប់ថវិការបស់ខ្លួន ។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬ មន្ទីរជំនាញខេត្ត- ក្រុង ដែលមិនបានបំពេញ និង ផ្តល់ព័ត៌មានគ្រប់គ្រាន់សំរាប់ការប្រជុំការពារថវិកាទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅអង្គភាពអោយបានទាន់ពេលវេលា ដើម្បីបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការ យកមូលដ្ឋាននៃថវិកាឆ្នាំ ២០០៨ ហើយប្រើគោលការណ៍កំណត់គញ្ចប់តាមជំពូក គណនី និង អនុគណនីខាង លើ សំរាប់កំណត់គំរោងថវិការបស់អង្គភាពនោះ ដើម្បីជាមូលដ្ឋានសំរាប់ការប្រជុំការពារថវិកា និង រៀបចំ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអោយបានទាន់ពេលវេលា ។

## ឃ- ការរៀបចំ និង ការវិភាគសំណើនានា

**២៣-** ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (n-1) ឆ្នាំ ២០០៨ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០៧ /០៣៥ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០០៩ ឆ្នាំ (n) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការ ទៅបាន ។ ក្រសួង- ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និង ការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតំរូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុ ដូចខាងក្រោម ÷

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា:
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែង ចែកឥណទានដើមនៃក្រសួង- ស្ថាប័ន ព្រមទាំងមន្ទីរជំនាញខេត្ត- ក្រុងមានការប្រែប្រួល ។
  - ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញ ខេត្ត- ក្រុង ។

• ផលប៉ះពាល់ដោយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និង ចំណាយរដ្ឋបាល ។ ល ។

២៤- គំរោងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៥- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៦- បច្ចេកទេសវិភាគដ៏ទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និង អត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ត្រូវតែបំរើទៅលើៈ

- គោលបំណង និងទិសដៅនៃគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និង មន្ទីរ ជំនាញខេត្ត-ក្រុងនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា
- កម្មវិធី និង យុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសំរេចបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន
- ផែនការសកម្មភាព និង រាល់មធ្យោបាយដំណើរការ ដើម្បីអនុវត្តកម្មវិធី និង យុទ្ធសាស្ត្រអាទិភាព
- ការគ្រប់គ្រង ការតាមដាន ការវាយតំលៃ និង ការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តកម្មវិធី និង យុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសំរាប់សំរេចបានគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។

## IV- សេចក្តីសន្និដ្ឋាន

២៧- ដើម្បីសំរេចបានតាមគោលដៅ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង ជាពិសេសការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង កំណើនខ្ពស់ជាមធ្យម ពី ៦ ទៅ ៧ ភាគរយ ប្រកបដោយចីរភាពគឺជាធនធានចាំបាច់ និង មិនអាចខ្វះបាន ។ ដើម្បីអោយធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់នោះគឺ ទាមទារអោយគ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវមាន ទិសដៅនៃគោលនយោបាយ និង គោលបំណង របស់ខ្លួនយ៉ាងច្បាស់លាស់ ដែលផ្សារភ្ជាប់ទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** មានកម្មវិធី និង យុទ្ធសាស្ត្រអាទិភាពជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវក្នុងការអនុវត្តឆ្ពោះទៅសំរេចអោយបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកំពស់អភិបាលកិច្ចល្អ តាមរយៈកម្មវិធីកែទំរង់

ស៊ីជំរៅលើគ្រប់វិស័យ ជាពិសេស ការកែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

២៨- ពេលទទួលសារាចរណែនាំនេះ *គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំជាបន្ទាន់នូវគំរោងចំណូល-ចំណាយថវិការបស់ខ្លួន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរ បំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨* ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់ការពិភាក្សាកំរិតជំនាញ និង បូកសរុបសំរាប់ការចរចាចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែសីហា ឆ្នាំ ២០០៨ ។ តួលេខគំរោងចំណូល-ចំណាយ ថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លានរៀល ។

២៩- ក្នុងការអនុវត្តសារាចរណែនាំនេះ បើក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"*ដើម្បីជូនជ្រាប*"

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

"*ដើម្បីមុខការ*"

- ឯកសារ-កាលប្បវត្តិ